## តើអ្វីជារោគរលាកថ្លើមប្រភេទ B?

រោគរលាកថ្លើមប្រភេទ B គឺជាវីរុសដែលវាយប្រហារថ្លើម។ ប្រសិនបើទុកចោលមិនព្យាបាល វាអាចធ្វើឱ្យថ្លើមមិនដំណើរការ និងកើតមហារីក។

មនុស្សប្រមាណ 296 លាននាក់កំពុងរស់នៅដោយមានផ្ទុករោគរលាកថ្លើមប្រភេទ B នៅទូទាំងពិភពលោក។ មនុស្សជាច្រើនមិនដឹងខ្លួនថាបានឆ្លងមេរោគ ដោយសារពួកគេមិនមានអារម្មណ៍ ឬមើលទៅដូចជាមានជំងឺទេ។

រោគរលាកថ្លើមប្រភេទ B ចម្លងពីមនុស្សទៅមនុស្សតាមរយៈឈាម ឬសារធាតុរាវនៃរាងកាយដែលមានមេរោគ។

## រោគរលាកថ្លើមប្រភេទ B និងការមានផ្ទៃពោះ

ប្រសិនបើអ្នកមានផ្ទៃពោះ អ្នកគួរតែធ្វើតេស្តឈាមរកមើលរោគរលាកថ្លើមប្រភេទ B ជាផ្នែកមួយនៃការថែទាំមុនពេលសម្រាលកូនរបស់អ្នក។

អ្នកអាចចម្លងរោគរលាកថ្លើមប្រភេទ B ទៅទារកទើបនឹងកើតរបស់អ្នកក្នុងអំឡុងពេលសម្រាលកូន ប្រសិនបើអ្នកបានឆ្លងមេរោគនេះ។

ប្រសិនបើអ្នកមានផ្ទៃពោះ និងមានផ្ទុករោគរលាកថ្លើមប្រភេទ B នោះទារករបស់អ្នកអាចចាក់ថ្នាំមួយឈុតចាប់ពីពេលសម្រាលកូន ដើម្បីបង្ការការចម្លង។



## សម្រាប់ព័ត៌មានបន្ថែម៖

**Centers for Disease Control and Prevention (CDC, មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺ)**
www.cdc.gov/hepatitis/hbv/

**HepB Moms**
www.hepbmoms.org (អង់គ្លេស)

HepBHub
doh.wa.gov/hepbhub

DOH 420-406 May 2022 Khmer

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនស្ដាប់មិនឮ ឬស្ដាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។

ប្រភព៖ CDC, Protect Your Baby for Life



# រោគរលាកថ្លើមប្រភេទ B៖ អ្វីដែលអ្នកត្រូវដឹងដើម្បីការពារខ្លួនអ្នក និងទារករបស់អ្នក

Washington State Department of Health



## តើរោគរលាកថ្លើមប្រភេទ B មានគ្រោះថ្នាក់ចំពោះកូនរបស់ខ្ញុំដែរទេ?

នៅពេលទារកឆ្លងរោគរលាកថ្លើមប្រភេទ B ពួកគេមានឱកាសប្រហែល 90% ដែលអាចវិវឌ្ឍទៅជាជំងឺរ៉ាំរ៉ៃអស់មួយជីវិត។

កុមារមានផ្ទុករោគរលាកថ្លើមប្រភេទ B រ៉ាំរ៉ៃប្រហែល 1 នាក់ក្នុងចំណោម 4 នាក់ដែលត្រូវបានទុកចោលមិនព្យាបាលនឹងវិវឌ្ឍទៅជាបញ្ហាថ្លើមធ្ងន់ធ្ងរ ដូចជាខូចថ្លើម ជំងឺថ្លើម ឬមហារីកថ្លើមជាដើម។

សំណាងល្អ យើងអាចបង្ការការចម្លងរោគរលាកថ្លើមប្រភេទ B ដោយប្រើវ៉ាក់សាំងដែលមានប្រសិទ្ធភាព និងសុវត្ថិភាពខ្ពស់។

## ការពារទារករបស់អ្នក និងបង្ការរោគរលាកថ្លើមប្រភេទ B

ទារករបស់អ្នកគួរតែចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B ដំបូង ក្នុងចន្លោះពេល 24 ម៉ោងបន្ទាប់ពីកើតមក។

ប្រសិនបើអ្នកមានផ្ទុករោគរលាកថ្លើមប្រភេទ B ទារករបស់អ្នកត្រូវតែចាក់ គ្លូប៊ុយលីនបង្កើនភាពស៊ាំប្រឆាំងនឹងរោគរលាកថ្លើមប្រភេទ B (HBIG) ក្នុងចន្លោះពេល 12 ម៉ោងបន្ទាប់ពីកើតមក។

ទារករបស់អ្នកត្រូវការវ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B ទាំង 3 និងចាក់ HBIG ដើម្បីការពារពួកគេពីរោគរលាកថ្លើមប្រភេទ B។ សូមធ្វើតេស្តទារករបស់អ្នកនៅអាយុ 9-12 ខែ ដើម្បីបញ្ជាក់ថាទារករបស់អ្នកត្រូវបានការពារ។

| កាលបរិច្ឆេទកំណត់ | ទារកកើតពីមនុស្សមានផ្ទៃពោះដែលមានផ្ទុករោគរលាកថ្លើមប្រភេទ B គួរតែចាក់ |
|---|---|
| នៅពេលកើត | ដូសសម្រាប់ពេលកើតនៃវ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B និង គ្លូប៊ុយលីនបង្កើនភាពស៊ាំប្រឆាំងនឹងរោគរលាកថ្លើមប្រភេទ B (HBIG) |
| **1–2 ខែ** | ដូសទី 2 នៃវ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B |
| **6 ខែ** | ដូសទី 3 នៃវ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B |
| **9–12 ខែ** | ធ្វើតេស្តដើម្បីបញ្ជាក់ថាទារករបស់អ្នកត្រូវបានការពារ |

នេះជាវិធីផ្សេងទៀតក្នុងការការពារទារករបស់អ្នក៖

- អ្នកនៅតែអាចបំបៅដោះកូនអ្នកបាន ប្រសិនបើអ្នកមានផ្ទុក រោគរលាកថ្លើមប្រភេទ B។ សូមពិគ្រោះជាមួយគ្រូពេទ្យ ប្រសិនបើចុងសុដន់របស់អ្នក ប្រេះ និងចេញឈាម។ មានជម្រើសដើម្បីជួយអ្នកក្នុងពេលបំបៅដោះកូន។
- រក្សាកំណត់ត្រាចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B របស់អ្នក ហើយយកវាទៅជាមួយ ពេលទៅជួបគ្រូពេទ្យ។
- នាំសមាជិកគ្រួសាររបស់អ្នកទៅធ្វើតេស្ត និងចាក់វ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B។

## ប្រសិនបើអ្នកមិនមានរោគរលាកថ្លើមប្រភេទ B ទេ

អ្នកនៅតែអាចការពារខ្លួនអ្នក និងទារករបស់អ្នក ដោយចាក់វ៉ាក់សាំងដែលមានសុវត្ថិភាព និងប្រសិទ្ធភាព។ ត្រូវប្រាកដថាចាក់ឱ្យបានគ្រប់ចំនួន!

| កាលបរិច្ឆេទកំណត់ | ទារកគួរតែចាក់ |
|---|---|
| នៅពេលកើត | ដូសសម្រាប់ពេលកើតនៃវ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B |
| 1–2 ខែ | ដូសទី 2 នៃវ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B |
| 6 ខែ | ដូសទី 3 នៃវ៉ាក់សាំងរោគរលាកថ្លើមប្រភេទ B |

## ថែទាំខ្លួនអ្នក ប្រសិនបើអ្នកមានរោគរលាកថ្លើមប្រភេទ B

អ្នកប្រហែលជាត្រូវធ្វើតេស្តបន្ថែម ដើម្បីពិនិត្យមើលសុខភាពថ្លើម និងមើលថាអ្នកត្រូវការព្យាបាលឬអត់។

ឱសថប្រឆាំងនឹងវីរុសអាចព្យាបាលមនុស្សជាច្រើនដែលមានផ្ទុករោគរលាកថ្លើមប្រភេទ B។ ប៉ុន្តែមិនមែនគ្រប់គ្នាសុទ្ធតែត្រូវការព្យាបាលនោះទេ។

ពិគ្រោះជាមួយគ្រូពេទ្យមុនពេលលេបថ្នាំតាមវេជ្ជបញ្ជា ឱសថតាមហាង អាហារបំប៉ន ឬវីតាមីនផ្សេងៗ ព្រោះថ្នាំមួយចំនួនអាចនឹងធ្វើឱ្យខូចថ្លើម។

អ្នកក៏អាចទទួលបានអត្ថប្រយោជន៍ពីវ៉ាក់សាំងរោគរលាកថ្លើមប្រភេទ A ផងដែរ។ បន្តទៅជួបគ្រូពេទ្យបន្ទាប់ពីសម្រាលកូនរួច ដើម្បីតាមដានការឆ្លងរោគ។